00287593

C22/5/27

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៧)
**កាលបរិច្ឆេទនៃឯកសារ៖** ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩
**ភាគីបញ្ជូន៖** ការិយាល័យសហព្រះរាជអាជ្ញា
**ភាសាដើម៖** អង់គ្លេស
**ប្រភេទឯកសារ៖** សាធារណៈ

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / MAR / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសំណើរបស់ អៀង សារី សុំសេចក្តីបង្គាប់ឲ្យ មន្ទីរពេទ្យកាល់ម៉ែត បង្ហាញចេញនូវកំណត់ត្រាវេជ្ជសាស្ត្រនានា របស់អៀង សារី និងព័ត៌មានផ្សេងៗទៀត**

---

**បញ្ជូនដោយ៖**
**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ជនត្រូវចោទ/ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី៖**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

C22/5/27

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ១៧)*

## ១. សេចក្តីផ្តើម

១. ក្នុងសំណើមួយដែលមានលក្ខណៈចម្រុះ ("សំណើ"), ដើមបណ្តឹងឧទ្ធរណ៍ សុំឱ្យអង្គបុរេជំនុំជម្រះ បង្គាប់ដល់មន្ទីរពេទ្យកាល់ម៉ែត ទីក្រុងភ្នំពេញ ("មន្ទីរពេទ្យ") ដើម្បីផ្តល់ (១) កំណត់ត្រាវេជ្ជសាស្ត្រទាំងអស់ ដែលជាប់ទាក់ទងនឹងរូបគាត់នៅមន្ទីរពេទ្យ និងដែលមានរក្សាទុកដោយវេជ្ជបណ្ឌិតប្រចាំការនៅ អ.វ.ត.ក គឺវេជ្ជបណ្ឌិត នេត ផល្លា ។ (២) បញ្ជីឈ្មោះគ្រូពេទ្យទាំងអស់ដែលបានព្យាបាលគាត់នៅមន្ទីរពេទ្យ និងតួនាទីរបស់គ្រូពេទ្យម្នាក់ៗទាំងនោះ និង (៣) ព័ត៌មានអំពីអ្វីដែលគេហៅថា "គណៈកម្មាធិការ" នៅមន្ទីរពេទ្យនេះ បើយោងតាមដើមបណ្តឹងឧទ្ធរណ៍ថា "ដែលដូចជាធ្វើការសម្រេចជាសារវន្តទៅលើការព្យាបាល[គាត់]"[1] ។

២. សហព្រះរាជអាជ្ញា ស្នើអង្គបុរេជំនុំជម្រះ ច្រានចោលសំណើនេះដោយឈរលើទឡ្ហីករណ៍មួយចំនួន ក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗទៀត ដូចតទៅ៖ (១) មិនបង្ហាញថាតើការដាក់នេះធ្វើឡើងនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ណាទេ ។ (២) សំណើមានលក្ខណៈចម្រុះ ខ្វះភាពជាក់លាក់ និងគ្មានខ្លឹមសារខាងផ្នែកអង្គហេតុ ។ (៣) សំណើស្វែងរកឯកសារ និងដំណោះស្រាយផ្សេងៗដែលហួសពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នេះ[2] ។ (៤) សំណើមិនបានបញ្ជាក់ពីមូលហេតុថាហេតុអ្វីបានជាដើមបណ្តឹងឧទ្ធរណ៍ មិនបានរកដំណោះស្រាយផ្លូវច្បាប់តាមរបៀបផ្សេងៗឱ្យអស់លទ្ធភាព ជាមួយសហចៅក្រមស៊ើបអង្កេត និងថាហេតុអ្វីអង្គសាលាឧទ្ធរណ៍ដូចជាអង្គបុរេជំនុំជម្រះជាដើម គួរតែចេញសេចក្តីបង្គាប់ដូចដែលខ្លួនបានស្វែងរកនេះ ពិសេសនៅក្នុងបណ្តឹងឧទ្ធរណ៍មួយដែលបញ្ហាសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ មិនដែលបានលើកឡើងជាសំខាន់ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅពេលពួកគេបានឆ្លងកាត់ដីការសម្រេចបន្តថិរវេលានៃការឃុំខ្លួនដែលបានតវ៉ានោះ ។

---

[1] *ករណីរបស់ អៀង សារី,* សំណើជាបន្ទាន់របស់លោក អៀង សារី សុំសេចក្តីបង្គាប់ឲ្យមន្ទីរពេទ្យកាល់ម៉ែត បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក អៀង សារី, ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩, C22/5/25, ERN 00285108-002785115, ទំព័រទី៦ [*ចាប់ពីនេះតទៅហៅថា* សំណើ] ។

[2] *ករណីរបស់ អៀង សារី,* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨, C22/5/1, ERN 00250393-00250412 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

00287595



## ២. សេចក្តីសង្ខេបបឋម

### *តាមបញ្ញត្តិច្បាប់ ជនដែលបានជាប់ឃុំមានសិទ្ធិទទួលបានកំណត់ត្រាវេជ្ជសាស្ត្រផ្ទាល់ខ្លួន*

៣. ចុងចោទនានាកំពុងស្ថិតក្នុងការឃុំខ្លួន និងមេធាវីការពារក្តីរបស់ពួកគេមានសិទ្ធិទទួលបានកំណត់ត្រាវេជ្ជសាស្ត្ររបស់ចុងចោទ ។ វាជាបទដ្ឋានអន្តរជាតិ ហើយដែលនៅក្នុងចំណោមឯកសារផ្សេងៗទៀត បទដ្ឋាននេះមានចែងនៅក្នុងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីតួនាទីរបស់មេធាវី ដែលមានការគាំទ្រចំពោះសិទ្ធិទទួលបានព័ត៌មានផ្នែកវេជ្ជសាស្ត្រដែលចែងថា "វាជាភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលត្រូវធានាឲ្យប្រាកដថា មេធាវីទទួលបានព័ត៌មាន សំណុំរឿង និងឯកសារនានាដែលស្ថិតនៅក្រោមការកាន់កាប់ ឬការត្រួតត្រារបស់ពួកគេដោយសមរម្យក្នុងពេលវេលាសមស្រប ដើម្បីបង្កលក្ខណៈឲ្យមេធាវីផ្តល់ជំនួយផ្នែកច្បាប់ដោយប្រសិទ្ធភាពដល់កូនក្តីរបស់ពួកគេ"[3] ។

៤. បទដ្ឋានអន្តរជាតិនេះត្រូវបានកំណត់យ៉ាងរឹងមាំនៅក្នុងវិធានស្តីពីការឃុំខ្លួនរបស់ អ.វ.ត.ក ។ វិធាន៥.៧.១ កត់សំគាល់ថា ព័ត៌មានដែលមាននៅក្នុងសំណុំឯកសារវេជ្ជសាស្ត្ររបស់ជនជាប់ឃុំ គឺជាការសម្ងាត់ និងគួរតែត្រូវបានបង្ហាញដល់ជនជាប់ឃុំ និងក្រុមមេធាវីការពារក្តីរបស់គាត់តែប៉ុណ្ណោះ ។

## ៣. សេចក្តីអះអាង

### *សំណើមិនបង្ហាញថាតើការដាក់នេះធ្វើឡើងនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ណាទេ*

៥. សំណើនេះមិនបង្ហាញថាតើការដាក់នេះធ្វើឡើងនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ណាទេ ។ សំណើក៏មិនបានលើកយោងនូវបទប្បញ្ញត្តិ ឬករណីយុត្តិសាស្ត្រដែលខ្លួនកំពុងតែស្វែងរកនូវសេចក្តីបង្គាប់ដែលមានការចងកាតព្វកិច្ចចំពោះអង្គបុរេជំនុំជម្រះ ដើម្បីបង្គាប់ទៅមន្ទីរពេទ្យឲ្យផ្តល់

---

[3] គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីតួនាទីរបស់មេធាវី, សមាជលើកទី៨ របស់អង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់បទឧក្រិដ្ឋ និងការប្រព្រឹត្តិចំពោះជនល្មើស, ទីក្រុងហាវ៉ាណា, ប្រទេសគុយបា, ថ្ងៃទី២៧ សីហា - ថ្ងៃទី៧ កញ្ញា ១៩៩០, និងកថាខ័ណ្ឌទី២១, អាចរកបានតាមគេហទំព័រ: http://www.unhchr.ch/html/menu3/b/h_comp44.htm ។

នូវកំណត់ត្រាវេជ្ជសាស្ត្រនោះដែរ ។ វាមិនបានបង្ហាញពីប្រភពណាមួយ ប្រសិនបើមាន និង វិសាលភាពនៃអំណាចដូច្នេះរបស់អង្គបុរេជំនុំជម្រះទេ ។

៦. ដោយសារអវត្តមាននៃភាពច្បាស់លាស់ សហព្រះរាជអាជ្ញាអាចគ្រាន់តែគិតស្ទង់មើលទៅលើមូលដ្ឋានផ្នែកច្បាប់នៃសំណើរបស់ដើមបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ ។ ប្រសិនបើសំណើត្រូវបានសន្មតថា បានដាក់ដោយស្នើឲ្យចេញ *សំណើសុំជំនួយ* ស្របតាមមាត្រា២៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀងរវាង អ.ស.ប-កម្ពុជា") នោះសំណើនេះគួរតែត្រូវបានបដិសេធចោល ដោយសារដើមបណ្តឹងឧទ្ធរណ៍មិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវ មុននឹងទទួលបាន *សំណើសុំជំនួយ* ណាមួយ[4] ។ វាជាករណីយុត្តិសាស្ត្រអន្តរជាតិដែលបានទទួលស្គាល់រួចហើយ ដែលថា ភាគីមួយដែលកំពុងស្វែងរកឲ្យមានការផ្តល់ឯកសារ ឬព័ត៌មានពីរដ្ឋមួយ ភាគីនោះត្រូវ៖

i. ចង្អុលប្រាប់អត្តសញ្ញាណឯកសារ ឬ ព័ត៌មាននោះ ថាតើពាក់ព័ន្ធដល់កំរិតណាទៅនឹងសំណើសុំនោះ តាមដែលអាចធ្វើទៅបាន ។

ii. បញ្ជាក់ពីកំរិតដែលពាក់ព័ន្ធទៅនឹងកិច្ចការណាមួយដែលកំពុងចោទឡើងនោះ នៅចំពោះមុខអង្គជំនុំជម្រះ ហើយប្រសិនបើចាំបាច់ ឲ្យមានការកំណត់សម្រេចពីបញ្ហានោះផង ។

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ [*ចាប់ពីនេះតទៅហៅថា* កិច្ចព្រមព្រៀងរវាង អ.ស.ប-កម្ពុជា] ។

iii. ពន្យល់ពីជំហាននានាដែលបានធ្វើដោយអ្នកស្នើសុំ ដើម្បីធានាឱ្យមានជំនួយរបស់រដ្ឋ[5] ។ អ្នកស្នើសុំមានកាតព្វកិច្ចបង្ហាញឱ្យឃើញថា មុននឹងស្វែងរកដំណោះស្រាយពីអង្គជំនុំជម្រះ ខ្លួនបានប្រឹងប្រែងដ៏សមហេតុសមផល ដើម្បីបញ្ចុះបញ្ចូលរដ្ឋនោះឱ្យផ្តល់ព័ត៌មានតាមសំណើដោយស្ម័គ្រចិត្ត[6] ។ វៀរលែងតែក្រោយពេលដែលរដ្ឋនោះ មិនបានផ្តល់ការគាំទ្រតាមសំណើតែប៉ុណ្ណោះ ទើបភាគីនោះស្នើសុំអង្គជំនុំជម្រះឱ្យចាត់វិធានការតាមទម្រង់ណាមួយមានលក្ខណៈចាប់បង្ខំ[7]។ ភាគីត្រូវតែបង្ហាញឱ្យអង្គជំនុំជម្រះយល់បានថា គេបានសុំជំនួយពីរដ្ឋាភិបាលតាមរយៈអង្គការរដ្ឋដ៏ត្រឹមត្រូវ ។ ការបញ្ជូនសំណើដោយចំពោះទៅ អាជ្ញាធរកាន់កាប់ឯកសារគឺមិនគ្រប់គ្រាន់ទេ ។ លក្ខន្តិកៈទាំងឡាយនៃតុលាការអន្តរជាតិ បានដាក់បង្គាប់ឱ្យរដ្ឋនានាបំពេញកាតព្វកិច្ចរបស់ខ្លួន តែមិនដាក់បង្គាប់ទៅលើអាជ្ញាធរនីមួយៗនោះទេ ដើម្បីធានាថាកាតព្វកិច្ចរបស់ពួកគេ ចំពោះតុលាការត្រូវបាន

---

[5] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងគូកន*, សេចក្តីសម្រេចលើសំណើរបស់ Sreten Lukic សុំឱ្យធ្វើវិសោធនកម្មវិធាន៥៤ស្ទួន, សំណុំរឿងលេខ៖ IT-05-87-T, ចុះថ្ងៃទី២៩ កញ្ញា ២០០៦, កថាខ័ណ្ឌទី ៦ ។

[6] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងគូកន*, សេចក្តីសម្រេចលើសំណើលើកទីពីររបស់ Dragoljub Ojdanic សុំឱ្យមានការបង្គាប់ដែលចងកាតព្វកិច្ច ស្របតាមវិធាន៥៤ស្ទួន, សំណុំរឿងលេខ៖ IT-05-87-T, ចុះថ្ងៃទី១៧ វិច្ឆិកា ២០០៥, កថាខ័ណ្ឌទី៧ ។

[7] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងគូកន*, សេចក្តីសម្រេចលើសំណើរបស់សហរដ្ឋអាមេរិក សុំឱ្យមានការពិនិត្យឡើងវិញ, សំណុំរឿងលេខ៖ IT-05-87-AR10ស្ទួន.២, ចុះថ្ងៃទី១២ ឧសភា ២០០៦, កថាខ័ណ្ឌទី៣២ ។

បំពេញ[8] ។ ទោះជាយ៉ាងនេះក៏ដោយក៏សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសំណើនេះ គឺមានលក្ខណៈតាមតែការសម្រេចចិត្ត[9] ។

៧. នៅពេលដែលបញ្ញត្តិ នៅក្នុងលក្ខន្តិកៈនានាសម្រាប់តុលាការអន្តរជាតិ យោងទៅដល់ពាក្យ “សេចក្ដីសម្រេច” ដែលអាចត្រូវបានចេញដោយអង្គភាពតុលាការណាមួយរបស់ពួកគេ ទៅកាន់រដ្ឋដែលជាប់ពាក់ព័ន្ធ នោះកិច្ចព្រមព្រៀងរវាង អសប-កម្ពុជា បានអនុញ្ញាតឱ្យ អង្គបុរេជំនុំជម្រះ ធ្វើសំណើសុំជំនួយ ពីរដ្ឋាភិបាលកម្ពុជាបាន[10] ។ បើសិន ជាដើមបណ្ដឹងឧទ្ធរណ៍ត្រូវគេសន្មតថា បានកំពុងតែស្វែងរកសំណើសុំជំនួយ ពីអង្គបុរេជំនុំជម្រះ នោះគាត់មិនបានបង្ហាញថា តើសំណើរបស់គាត់ ត្រូវទៅតាមលក្ខខណ្ឌទាំងបីខាងលើនេះតាមរបៀបណានោះទេ ។ គាត់៖ ទី១) មិនបានធ្វើការកំណត់ឱ្យបានជាក់លាក់ និង “ច្បាស់លាស់”[11] អំពីថាតើឯកសារណាមួយ ដែលគាត់មានបំណងចង់បាននោះទេ ទី២) មិនបានបញ្ជាក់អំពីរបៀបដែលឯកសារទាំងនោះ មានជាប់ពាក់ព័ន្ធក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ននេះទេ, និង ទី៣) មិនបានពន្យល់អំពីជំហាននានា ដែលគាត់នឹងប្រកាន់យកដើម្បីធានាឱ្យបាននូវជំនួយពីរដ្ឋមុននឹងគាត់ចាប់ផ្ដើមដាក់សំណើនេះ។ ហេតុដូច្នេះ សំណើនេះ គួរតែត្រូវបានច្រានចោល ។

### *សំណើមានលក្ខណៈចម្រុះ ខ្វះភាពជាក់លាក់ និងគ្មានខ្លឹមសារផ្អែកអង្គហេតុ*

---

[8] *រដ្ឋអាជ្ញា ទល់នឹង Halilovic*, សេចក្ដីសម្រេចលើញត្តិស្នើសុំសិទ្ធិ, សំណុំរឿងលេខ៖ IT-01-48-PT, ចុះថ្ងៃទី៤ ធ្នូ ២០០៣, ទំព័រទី២។

[9] *រដ្ឋអាជ្ញា ទល់នឹង Milutinovic និងគូកន*, សេចក្ដីសម្រេចលើសំណើរបស់ Sreten Lukic សុំឱ្យធ្វើវិសោធនកម្មវិធាន៥៤ស្ទួន, សំណុំរឿងលេខ៖ IT-05-87-T, ចុះថ្ងៃទី២៩ កញ្ញា ២០០៦, កថាខ័ណ្ឌទី ៧ ។

[10] ជាឧទាហរណ៍ ប្រៀបធៀបមាត្រា២៥ នៃកិច្ចព្រមព្រៀងអសប-កម្ពុជា ជាមួយនឹងមាត្រា ២៩ នៃលក្ខន្តិកៈសម្រាប់តុលាការ ICTY ឬ ជាមួយនឹងវិធាន ៥៤ស្ទួន នៃវិធានស្ដីពីភស្ដុតាងនិងនីតិវិធី សម្រាប់តុលាការ ICTY ។

[11] *ករណីរបស់ អៀង សារី*, សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រ ដើម្បីផ្ដល់ភស្តុតាងនាពេលសវនាការដោយផ្ទាល់មាត់ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២៣ កុម្ភៈ ២០០៩, C22/5/18, ERN 00282884-00282888, កថាខណ្ឌទី ១៤ [*ចាប់ពីនេះតទៅហៅថា* សេចក្ដីសម្រេចបដិសេធសំណើចម្រុះ] ។

៨. សំណើនេះ មិនមានភាពជាក់លាក់ និងថែមទាំងទូលំទូលាយពេកទៀតផង ។ សំណើនេះសុំឱ្យមានការបង្ហាញនូវ "គ្រប់កំណត់ត្រាវេជ្ជសាស្ត្រ ដែលមានជាប់ទាក់ទងនឹងការចូលទៅសម្រាកពេទ្យជាញឹកញាប់របស់ដើមបណ្តឹងឧទ្ធរណ៍ និងរបាយការណ៍ប្រចាំថ្ងៃរបស់វេជ្ជបណ្ឌិតប្រចាំការនៅអ.វ.ត.ក"[12]។ ឯកសារទាំងនេះមានជាប់ទាក់ទងនឹងរយៈពេលច្រើនជាងដប់ប្រាំ (១៥) ខែ នៃការឃុំខ្លួន ដើមបណ្តឹងឧទ្ធរណ៍នៅឯមន្ទីរឃុំឃាំងរបស់អ.វ.ត.ក ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានកំណត់អំពីរយៈពេលឱ្យបានជាក់លាក់ ឬរបាយការណ៍ណាមួយ ឱ្យបានជាក់លាក់ ឬផ្នែកណាមួយនៃរបាយការណ៍ឱ្យបានជាក់លាក់ ក្នុងការដែលគាត់ចង់ឱ្យមានការបង្ហាញនោះទេ ។ នៅពេលដែលគាត់ធ្វើការកំណត់អំពីឯកសារ គឺគាត់បានធ្វើទៅតាមរបៀបមួយដែលទូលំទូលាយ [ដោយមិនបានរកអង្គហេតុមកបញ្ជាក់ទេ] ។ ឧទាហរណ៍ ដើមបណ្តឹងឧទ្ធរណ៍ចង់ឱ្យមានការបង្ហាញរបាយការណ៍ប្រចាំថ្ងៃទាំងអស់ របស់វេជ្ជបណ្ឌិតដែលប្រចាំការនៅអ.វ.ត.ក ក្នុងរយៈពេលដប់ប្រាំ (១៥) ខែចុងក្រោយទាំងស្រុង ។ សំណើរបស់ដើមបណ្តឹងឧទ្ធរណ៍សុំឈ្មោះ និងតួនាទីរបស់វេជ្ជបណ្ឌិតទាំងអស់ដែលបានពិនិត្យគាត់ និងសេចក្តីពិស្តារអំពីអ្វីដែលគេហៅថា "គណៈកម្មាធិការ" គឺមានលក្ខណៈស្រពិចស្រពិលដូចគ្នា ។

៩. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធសំណើនេះចោល ដោយសារសំណើនេះមានលក្ខណៈស្រពិចស្រពិល និងទូលំទូលាយ [ដោយមិនបានរកអង្គហេតុមកបញ្ជាក់ទេ] ។

## *សំណើស្វែងរកឯកសារ និងការដោះស្រាយនានាដែលហួសពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍*

១០. សំណើស្វែងរកឯកសារ ដែលបានធ្វើឡើងក្នុងរយៈពេលដប់ប្រាំ (១៥) ខែចុងក្រោយ ។ មានតែមួយរយៈពេលខ្លីប៉ុណ្ណោះដែលឋិតនៅក្នុងវិសាលភាពនៃដំណើរការនីតិវិធីទាំងនេះ។ បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធទៅនឹង ការបន្តថិរវេលានៃការឃុំខ្លួន ដែលបានអនុញ្ញាតដោយសហចៅ

---

[12] សំណើ, ទំព័រទី ៦ ។

ក្រុមស៊ើបអង្កេត ចាប់តាំងពី ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៨ មកម្ល៉េះ ។ ហេតុដូច្នេះ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះនេះ នៅក្នុងដំណើរការនីតិវិធីនេះ គឺថាតើការបន្តថិរវេលានៃការឃុំខ្លួនគឺត្រឹមត្រូវដែរឬទេ ឬថាតើលក្ខខណ្ឌនៃការឃុំខ្លួនទៅតាមវិធាន៦៣.៣ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ធ្វើបានត្រឹមត្រូវដែរឬទេ ហើយថានៅតែត្រឹមត្រូវដែរឬទេ រហូតដល់ពេលនេះ ។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយ ដោយរក្សាទុកនូវការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេតតាំងពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៧[13] ។ នៅក្នុងសាលដីកានេះ អង្គបុរេជំនុំជម្រះនេះបានវិភាគលើគ្រប់ឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង (ដោយរាប់បញ្ចូលទាំងរបាយការណ៍វេជ្ជសាស្ត្រពីមន្ទីរពេទ្យ និង របាយការណ៍វេជ្ជសាស្ត្រ ដែលបានដាក់ជូនដោយវេជ្ជបណ្ឌិត នេត ផល្លាផង) ហើយបានសម្រេចថា “គ្មានភស្តុតាងដែលជាតម្រូវការបន្ទាន់នៃការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ក្នុងរយៈពេលយូរឡើយ ហើយមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក បានបំពាក់នូវសម្ភារៈនិងឧបករណ៍ត្រឹមត្រូវសម្រាប់ផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រទៅតាមតម្រូវការ”[14] ។ នៅក្នុងសាលដីកាមួយ ដាច់ដោយឡែក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ជាថ្មីម្តងទៀត មានការធ្វើការវិភាគលើគ្រប់កំណត់ហេតុវេជ្ជសាស្ត្រទាំងអស់ ដែលមាននៅក្នុងសំណុំរឿង ហើយអង្គជំនុំជម្រះនេះបានធ្វើការកត់សម្គាល់ថា៖

> “[...] គ្មានរបាយការណ៍វេជ្ជសាស្ត្រណាមួយ ឬរបាយការណ៍អ្នកជំនាញណាម្នាក់បញ្ជាក់ថា គឺមកពីជម្ងឺទាំងអស់នោះហើយដែលអាចធ្វើឲ្យ មានការប៉ះពាល់ទៅលើសមត្ថភាពស្មារតីរបស់ជនត្រូវចោទនោះឡើយ ។ គេមិនឃើញមានការបញ្ជាក់អំពីផលប៉ះពាល់ដែលបានបង្កឡើងដោយការប្រើប្រាស់ឱសថណាមួយឡើយ ។ ផ្ទុយទៅវិញ គ្រូពេទ្យឯកទេសផ្នែកបេះដូង Antoine Lafont និង ជួរ សុខ (CHOUR

---

[13] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ អៀង សារី, ចុះថ្ងៃទី១៧ តុលា ២០០៨, C22/1/73, ERN 00232830-00232861 [*ចាប់ពីនេះតទៅហៅថា* សាលដីកា ចុះថ្ងៃទី១៧ តុលា ២០០៨] ។

[14] សាលដីកា, ចុះថ្ងៃទី១៧ តុលា ២០០៨, កថាខណ្ឌទី ១២៣ ។

Sok) ដែលត្រូវបានចាត់តាំងជាអ្នកជំនាញ បានធ្វើការសន្និដ្ឋាននៅក្នុងរបាយការណ៍ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ថាជម្ងឺដែលពួកគាត់បានរកឃើញនោះមិនចាំបាច់តម្រូវឲ្យមានវិធានការដាក់លាក់ ទាក់ទងទៅនឹងការចូលរួមរបស់ជនត្រូវចោទក្នុងកិច្ចស៊ើបសួរនោះឡើយ"[15] ។

១១. បណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ននេះមិនមែនជាបណ្ដឹងឧទ្ធរណ៍ធម្មតាមួយស្ដីពីការឃុំខ្លួននោះទេ ។ នេះគឺជាបណ្ដឹងឧទ្ធរណ៍មួយដែលប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនដែលត្រូវធ្វើវិភាគទៅលើឯកសារដែលស្ថិតនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ នឹងអំពីថា តើសហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនសមស្របដែរឬទេ ។ ការផ្លាស់ប្ដូរកាលៈទេសៈជាក់ស្ដែងណាមួយក្រោយពីនេះទៀត គួរតែបានក្លាយទៅជាមូលហេតុមួយ ដែលបណ្ដាលឲ្យមានជាការដាក់ពាក្យសុំដោះលែងជាបណ្ដោះអាសន្នថ្មីស្រឡាងមួយ ដើម្បីបើកឲ្យគ្រប់ភាគីទាំងអស់អាចមានឱកាសក្នុងការធ្វើសារណាឲ្យបានពេញលេញជូនសហចៅក្រមស៊ើបអង្កេត និងដើម្បីឲ្យបានប្រកបទៅដោយអត្ថន័យសម្រាប់ឲ្យស្ថាប័នឧទ្ធរណ៍ធ្វើចំណាត់ការក្រោយពីនេះទៀត ។ ការដែលនាំយកនូវភស្តុតាងថ្មីស្រឡាងដែលមិនទាន់បានសាកពិសោធន៍នៅឡើយមកជូនចំពោះមុខស្ថាប័នឧទ្ធរណ៍មួយ - តួយ៉ាងដូចជា អង្គបុរេជំនុំជម្រះនេះ - គឺជាការធ្វើឲ្យបរាជ័យដល់គោលដៅដ៏មានសារប្រយោជន៍ទាំងឡាយដែលស្ថាប័នឧទ្ធរណ៍នេះត្រូវពិនិត្យមើលឡើងវិញ ។

១២. ដើមបណ្ដឹងឧទ្ធរណ៍ មិនបានបង្ហាញឲ្យឃើញថា តើកាលៈទេសៈជាក់ស្ដែងណាមួយបានផ្លាស់ប្ដូរនៅក្នុងស្ថានភាពសុខភាពរបស់ខ្លួននោះទេ ដើម្បីបើកឱកាសឲ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើការរកឃើញរបស់ខ្លួន និងដើម្បី "ចេញដីកាបង្គាប់" ឲ្យធ្វើការបង្ហាញជូននូវឯកសារនានាពីមន្ទីរពេទ្យ ដែលរំលងមិនបានពិនិត្យ និងពីលើឯកសារទាំងឡាយដែល

[15] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ, ចុះថ្ងៃទី២១ តុលា ២០០៨, A189/1/8, ERN 00233433-00233443, កថាខណ្ឌទី ៤៣ ។

អង្គជំនុំជម្រះបានពិនិត្យពិចារណារួចហើយ និងដែលបានធ្វើការសម្រេចផ្អែកតាមនោះ ។ គាត់ក៏មិនបានបង្ហាញឱ្យឃើញអំពីស្ថានភាពសុខភាពគាត់ថា តើវាមានការផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះនោះដែរចាប់តាំងពីពេលដាក់បណ្តឹងឧទ្ធរណ៍នេះមក ដើម្បីនឹងតម្រូវចាំបាច់ឱ្យធ្វើការបង្ហាញជូននូវឯកសារដែលគាត់មិនបានស្វែងរក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ អង្គបុរេជំនុំជម្រះ បានធ្វើការកត់សំគាល់រួចហើយថា នៅក្នុងសារណាលើបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងនូវបញ្ហាណាមួយទាក់ទិនស្ថានភាពសុខភាពរបស់គាត់នោះទេ លើកលែងតែប្រយោគខ្លីមួយនៅក្នុងកថាខណ្ឌទី៥៣ ដែលបានធ្វើការយោងជាទូទៅមួយទៅលើ "វ័យចាស់ និងសុខភាពដែលមានជម្ងឺ" របស់គាត់តែប៉ុណ្ណោះ[16] ។ ជាពិសេស បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធទៅនឹងបញ្ហានៃការយកចិត្តទុកដាក់ហ្មត់ចត់ ក្នុងការស៊ើបសួរ និងការមិនពិចារណាជាមុននូវជម្រើសផ្សេងៗនៃរបៀបឃុំខ្លួន(ដូចជាការឃុំខ្លួនក្នុងផ្ទះជាដើម) ពីសំណាក់សហចៅក្រមស៊ើបអង្កេត[17] ។ បញ្ហាស្តីពីសុខភាពរបស់ ដើមបណ្តឹងឧទ្ធរណ៍ ក៏មិនត្រូវបានលើកឡើងជាខ្លឹមសារសំខាន់អ្វីដែរនៅក្នុងការជំទាស់របស់ ដើមបណ្តឹងឧទ្ធរណ៍ទៅនឹងការបន្តចិរវេលានៃការឃុំខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[18] ។ ហេតុដូច្នេះហើយ ដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួន មិនបានពិចារណាទៅលើបញ្ហាសុខភាពទេនៅពេលដែលធ្វើសេចក្តីសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[19] ។

១៣. អង្គបុរេជំនុំជម្រះ ក៏បានធ្វើការកត់សំគាល់ផងដែរថា ដើមបណ្តឹងឧទ្ធរណ៍ថែមទាំងមិនបានបង្ហាញឱ្យឃើញពីអត្តសញ្ញាណនៃកាលៈទេសៈថ្មីណាមួយ ដើម្បីឱ្យសន្និដ្ឋានថា ស្ថានភាពសុខភាពរបស់គាត់គឺមានសភាព "ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនានាដែលមានស្រាប់មក

---

[16] សេចក្តីសម្រេចបដិសេធសំណើចម្រុះ, កថាខណ្ឌទី៨ ។

[17] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១ ។

[18] *ករណីរបស់ អៀង សារី,* ពាក្យសុំរបស់ អៀង សារី ប្រឆាំងនឹងការបន្តចិរវេលាឃុំខ្លួន, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨, C22/3, ERN 00235370-00235379 ។ បញ្ហាសុខភាពត្រូវបានសរសេរជាសំខាន់នៅក្នុងប្រយោគមួយក្នុងកថាខ័ណ្ឌទី១៦ ដែលនិយាយថា "លោក អៀង សារី មានវ័យជាង៨០ ឆ្នាំ ហើយត្រូវបានប្រញាប់ប្រញាល់បញ្ជូនទៅមន្ទីរពេទ្យជាញឹកញាប់" ។

[19] *ករណីរបស់ អៀង សារី,* ដីកាសម្រេចអំពីការបន្តចិរវេលាឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨, C22/4, ERN 00238566-00239537 ។

ហើយនោះទៀតផង"[20] ។ ជាបន្ថែមពីលើនេះ នៅក្នុងសេចក្តីសន្និដ្ឋានដាក់ជូនរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងឧទ្ធរណ៍មិនបានលើកឡើងនូវសំអាងថ្មីៗដែលមាន "លក្ខណៈជាក់លាក់" ដើម្បីនឹងអនុញ្ញាតឲ្យគាត់ធ្វើសំណើសុំឡើងវិញជាថ្មីម្តងទៀតដើម្បីពិនិត្យលើអ្នកជំនាញ និងដោយធ្វើការបន្តថិរវេលានៃការបង្ហាញជូនឯកសារផ្សេងៗបន្តទៀត នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ ។

១៤. ឯកសារវេជ្ជសាស្ត្រដែលបានដាក់នៅក្នុងសំណុំរឿងជាប់ទាក់ទងទៅនឹងរយៈពេល ចាប់តាំងពីការដាក់បណ្តឹងឧទ្ធរណ៍នេះមក (គឺបានសេចក្តីថា បន្ទាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ មក) គឺបង្ហាញឲ្យឃើញថា ស្ថានភាពសុខភាព និង រោគវិនិច្ឆ័យរបស់ដើមបណ្តឹងឧទ្ធរណ៍មិនមានការផ្លាស់ប្តូរនោះទេ ។ ឧទាហរណ៍ដូចជា ការចូលទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យលើកក្រោយបង្អស់នេះ ក្នុងអម្លុងពេលពីថ្ងៃទី២៣-២៥ ខែកុម្ភៈ ឆ្នាំ២០០៩នេះ គឺបណ្តាលមកពីមានឈាមនៅក្នុងទឹកម៉ូត្រ ដែលជាស្ថានភាពមួយដែលធ្លាប់មានពីមុនរួចមកហើយក្នុងប្រវត្តិនៃស្ថានភាពសុខភាពរបស់គាត់ ចាប់តាំងពីមុនពេលគាត់ត្រូវបានចាប់ខ្លួនមកម្ល៉េះ[21] ។ អ្នកជំនាញវេជ្ជ-សាស្ត្រ ដែលបានចាត់តាំងដោយសហចៅក្រមស៊ើបអង្កេតបានកត់សំគាល់ថា "ចាប់ពីបញ្ហាតម្រងនោម រោគសញ្ញា[របស់ដើមបណ្តឹងឧទ្ធរណ៍] គឺមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការរីកប្រូស្តាតកំរិតស្រាល (benign prostatic hyperplasia) ដែលបានព្យាបាលដោយការធ្វើអន្តោកម្មក្នុងសរីរាង្គក្នុងឆ្នាំ២០០៣ ហើយបច្ចុប្បន្នត្រូវបាននិងកំពុងតែព្យាបាល [...]"[22] ។ អ្នកជំនាញទាំងនោះបានបញ្ចេញយោបល់ថា "ការព្យាបាលប្រឆាំងនឹងការរាំងស្ទះក្នុងតម្រងនោម សម្រាប់ស្ថានភាពនេះអាចឲ្យគេគ្រប់គ្រងបាន "នៅឆ្ងាយពីផ្ទះ រួមទាំងនៅកន្លែងឃុំ

---

[20] សេចក្តីសម្រេចបដិសេធសំណើចម្រុះ, កថាខ័ណ្ឌទី១៤ ។

[21] សេចក្តីសម្រេចបដិសេធសំណើចម្រុះ, កថាខ័ណ្ឌទី១៤ ។

[22] *ករណីរបស់ អៀង សារី,* របាយការណ៍របស់វេជ្ជបណ្ឌិតស្តីពីស្ថានភាពសុខភាពរបស់ អៀង សារី នៅពេលព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩, ERN 00284552-00284552 ។ សូមអានផងដែរ *ករណីរបស់ អៀង សារី,* របាយការណ៍របស់អ្នកជំនាញ Drs MANGIN និង KOUTCH Hach, ចុះថ្ងៃទី១៤ ឧសភា ឆ្នាំ២០០៨, ERN 00189153-00189160, ទំព័រទី៥ [*ចាប់ពីនេះតទៅហៅថា* របាយការណ៍របស់ MANGIN] ។

ឃាំង ។ សម្រាប់ការចាត់ចែងទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់ វាជាការចាំបាច់ ដើម្បីផ្តល់ឱ្យមានបង្គន់អនាម័យមួយដែលនៅជិត ឬចង់ផ្លាស្ទិកសម្រាប់នោម"[23] ។

១៥. នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានធ្វើការពិនិត្យឡើងវិញតាមផ្លូវច្បាប់ជាមួយនឹងដើមបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់ ។ ក្នុងអំឡុងពេលសម្ភាស ដែលបានចូលរួមពីសំណាក់ក្រុមមេធាវីការពារក្តីរបស់គាត់ផងនោះ គាត់មិនបានពោលត្អូញត្អែរអ្វីអំពីផ្នែកសំខាន់ណាមួយនៃការឃុំខ្លួនរបស់គាត់ នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ឡើយ ។ សំណើរបស់គាត់តែមួយគត់ គឺសុំឱ្យមានការផ្លាស់ប្តូរមុខម្ហូបអាហាររបស់គាត់មួយចំនួនតែប៉ុណ្ណោះ[24] ។ ចម្លើយតបរបស់ដើមបណ្តឹងឧទ្ធរណ៍ គឺមាន លក្ខណៈស្រដៀងគ្នា នៅអំឡុងពេលសម្ភាសលើកមុន ជាមួយនឹងសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨[25] ។

១៦. ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះ បដិសេធចោលនូវសំណើដែលសុំឱ្យបង្ហាញនូវឯកសារនានា ដោយសារមូលហេតុថា សំណើនេះមិនមានការចង្អុលបង្ហាញភស្តុតាងនោះទេ ហើយព្រមទាំងស្ថិតនៅក្រៅពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នេះទៀតផង ។

***ដើមបណ្តឹងឧទ្ធរណ៍មិនបានប្រើអស់គ្រប់វិធីដំណោះស្រាយតាមផ្លូវច្បាប់ដែលជាជំរើសក្រៅពីនេះទេ មុននឹងស្វែងរកវិធីដោះស្រាយតាមរយៈអង្គបុរេជំនុំជម្រះនេះ***

---

[23] របាយការណ៍របស់ MANGIN, ទំព័រទី៨ ។

[24] *ករណីរបស់ អៀង សារី,* កំណត់ហេតុនៃការសាកសួរទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨, C44, ERN 00250650-00250652 ។

[25] *ករណីរបស់ អៀង សារី,* កំណត់ហេតុនៃការសាកសួរទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨, C32, ERN 00185518-00185521 (ការត្អូញត្អែរមាននៅលើទំព័រ៣ អំពីមិនមានរបបអាហារសម្រាប់គាត់ និងសម្លេងរំខាននៅក្នុងមន្ទីរឃុំឃាំង) ។

១៧. ដើមបណ្តឹងឧទ្ធរណ៍នេះបាននិយាយថា នៅក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០០៨ គាត់បានស្វែងរកឯកសារមួយចំនួនពីមន្ទីរពេទ្យដែលត្រូវបានគេបដិសេធ[26] ។ គាត់ក៏បានពោលអះអាងផងដែរថាក្នុងខែកុម្ភៈ ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់សិទ្ធិរបស់ជនជាប់ឃុំក្នុងការពិនិត្យមើលឯកសារពេទ្យទាំងឡាយរបស់គាត់ ដែលត្រូវបានគេរក្សាទុកនៅឯមន្ទីរឃុំឃាំងរបស់អ.វ.ត.ក និងនៅឯមន្ទីរពេទ្យ[27] ។ ក៏ប៉ុន្តែដើមបណ្តឹងឧទ្ធរណ៍នេះខកខានមិនបានបង្ហាញសក្ខីកម្មថា តើគាត់បានចាត់វិធានការអ្វីខ្លះហើយ ចាប់តាំងពីពេលនោះមក ដើម្បីស្នើសុំទៅមន្ទីរពេទ្យ និងរដ្ឋាភិបាលកម្ពុជាឱ្យបង្ហាញនូវឯកសារទាំងឡាយដែលបច្ចុប្បន្ននេះ គាត់កំពុងតែស្វែងរកតាមរយៈអង្គបុរេជំនុំជម្រះនោះទេ ។ គាត់ថែមទាំងមិនបានបង្ហាញឱ្យឃើញថា គាត់បានស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់សព្វគ្រប់វិធីអស់ហើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឱ្យសហចៅក្រមនេះជួយអន្តរាគមន៍ដើម្បីឱ្យបានទទួលនូវឯកសារទាំងនេះទៀតផង ។ គាត់ក៏មិនបានផ្តល់សក្ខីកម្មឱ្យឃើញអំពីថា តើហេតុអ្វីបានជាគាត់មិនបែរមករកអង្គបុរេជំនុំជម្រះវិញក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតមិនមានឆន្ទៈ ឬមិនមានលទ្ធភាពក្នុងការចេញដីកាកោះឱ្យយកមកនូវឯកសារទាំងនេះបាន ។

១៨. ដោយមិនបានប្រើអស់គ្រប់វិធីដំណោះស្រាយរបស់ខ្លួនជាមួយរដ្ឋាភិបាលកម្ពុជា (ដែលគ្រប់គ្រងមន្ទីរពេទ្យ) និង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត សម្រាប់រយៈពេលដប់ប្រាំ (១៥) ខែកន្លងទៅនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចត្រូវបានអនុញ្ញាតឱ្យស្វែងរកសុំឱ្យអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ឱ្យផ្តល់នូវឯកសារពេទ្យទាំងស្រុងរបស់គាត់បានទេ ជាពិសេសនៅពេលបញ្ហាដែលមានកំរិតនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ពាក់ព័ន្ធទៅនឹងការបន្តថិរវេលានៃការឃុំខ្លួនដែលគិតមកទល់ត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះ បដិសេធចោលសំណើនេះ ដោយសារមូលហេតុមិនទាន់ប្រើអស់គ្រប់វិធីដំណោះស្រាយជាមួយរដ្ឋ និង/ឬ ជាមួយសហចៅក្រមស៊ើបអង្កេត ។

---

[26] សំណើ, ទំព័រទី១៣ ។

[27] សំណើ, ទំព័រទី១៣ ។

## ៤. សេចក្តីសន្និដ្ឋាន

១៩. ដោយមូលហេតុដូចលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធសំណើនេះចោលទាំងស្រុង ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក Robert PETIT**